**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១០ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យដោះស្រាយការជីករណ្តៅដីនៅភូមិសាស្ត្ររាជធានីភ្នំពេញ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យដោះស្រាយការជីករណ្តៅដីនៅភូមិសាស្ត្ររាជធានីភ្នំពេញ ដែលមានសមាសភាព ដូចខាងក្រោម ៖

www.pheakdeylaw.com

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ប្រធាន |
| ២- | អភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣- | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៤- | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- | តំណាងក្រសួងការពារជាតិ | សមាជិក |
| ៦- | តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- | អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានរ៉ែ | សមាជិកអចិន្ត្រៃយ៍ |
| ៩- | អភិបាលខណ្ឌដង្កោ | សមាជិក |
| ១០- | អភិបាលខណ្ឌឬស្សីកែវ | សមាជិក |
| ១១- | អភិបាលខណ្ឌមានជ័យ | សមាជិក |
| ១២- | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ | លេខាអចិន្ត្រៃយ៍ |

សមាជិកគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យដោះស្រាយការជីករណ្តៅដីនៅភូមិសាស្ត្ររាជធានីភ្នំពេញ មានភារកិច្ច :

- ចុះពិនិត្យដល់ទីកន្លែង ដើម្បីសិក្សា និងដាក់ចេញនូវវិធានការណ៍នានា សំដៅអនុវត្តឱ្យមានប្រសិទ្ធភាព តាមខ្លឹមសារលិខិតលេខ ៩៦៤ សជណ.ឧស ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្សព្វផ្សាយដល់អាជីវករពាក់ព័ន្ធ អំពីខ្លឹមសារនៃសេចក្តីជូនដំណឹង លេខ ៩៦៤ សជណ.ឧស ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ របស់ទីស្តីទីការគណៈរដ្ឋមន្ត្រី
- អញ្ជើញម្ចាស់ដី ឬ អាជីវករពាក់ព័ន្ធ មកដោះស្រាយអំពីការកែលំអ និងលុបរណ្តៅដីទាំងអស់ ដែលបានជីកយកដីហួសកម្រិតបច្ចេកទេស ដើម្បីការពារបរិស្ថាន និងធានាសុវត្ថិភាពដល់ការរស់នៅ និងការធ្វើដំណើរទៅមករបស់ប្រជាពលរដ្ឋ
- កំណត់ទីតាំងជីកថ្មីជំនួសទីតាំងចាស់ដែលត្រូវយកអាចម៍ដីមកលុប ឬ រឹបអូសជាសម្បត្តិរដ្ឋ តាមច្បាប់ និងនីតិវិធីជាធរមាន
- កំណត់ពេលវេលាក្នុងការដឹកជញ្ជូន ដើម្បីសុវត្ថិភាពសង្គម

-

- តម្រូវឱ្យបង់សួយសារជូនរដ្ឋ ចំពោះរណ្តៅដីដែលបានជីករួច តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- បូកសរុប និងរាយការណ៍ពីលទ្ធផលនៃការពិនិត្យដោះស្រាយការជីករណ្តៅដីនៅតាមតំបន់នីមួយៗ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣.-**

គណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យដោះស្រាយការជីករណ្តៅដីនៅភូមិសាស្ត្ររាជធានីភ្នំពេញ មានសិទ្ធិស្នើសុំកងកម្លាំងប្រដាប់អាវុធ ជួយអន្តរាគមន៍ក្នុងករណីចាំបាច់ ។

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យដោះស្រាយការជីករណ្តៅដីនៅភូមិសាស្ត្ររាជធានីភ្នំពេញ មានលេខាធិការដ្ឋានមួយប្រចាំនៅអគ្គនាយកដ្ឋានធនធានរ៉ែ និងមានសិទ្ធិប្រើប្រាស់ត្រាររបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ អភិបាលខណ្ឌពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៥ ✓
- កាលប្បវត្តិ-ឯកសារ

www.pheakdeylaw.com